**Ministry of Foreign Affairs and**
**International Cooperation**
**Kingdom of Cambodia**
**OFFICE OF THE SPOKESPERSON**

# បច្ចុប្បន្នភាពស្ដីពីស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ
# ថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០២៥

**I. សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានស្នើឯកឧត្តម អានវ៉ា អ៊ីប្រាហ៊ីម ធ្វើអន្តរាគមន៍ជាបន្ទាន់ ដើម្បីបន្ធូរភាពតានតឹងរវាងកងកម្លាំងប្រដាប់អាវុធថៃ និងប្រជាពលរដ្ឋស៊ីវិលកម្ពុជា**

នៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០២៥ សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជួបសន្ទនាតាមទូរស័ព្ទជាមួយ ឯកឧត្តម អានវ៉ា អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងជាប្រធានអាស៊ានបច្ចុប្បន្ន។ ក្នុងកិច្ចសន្ទនាគ្នានោះ ថ្នាក់ដឹកនាំទាំងពីរ បានពិភាក្សាអំពីការវិវត្តនៃអំពើហឹង្សា ដែលបានប្រព្រឹត្តដោយកងកម្លាំងទាហាន និងប៉ូលីសថៃ លើប្រជាពលរដ្ឋកម្ពុជា នៅភូមិព្រៃចាន់ ឃុំអូបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលបណ្ដាលឱ្យមានរបួសធ្ងន់ស្រាលជាច្រើននាក់។

ក្នុងបរិបទស្ថានការណ៍កំពុងតែកើនឡើងនូវភាពតានតឹងនេះ សម្ដេចធិបតីនាយករដ្ឋមន្ត្រី បានអំពាវនាវដល់ ឯកឧត្តម អានវ៉ា ចូលរួមអន្តរាគមន៍ ដើម្បីបន្ថយភាពតានតឹងរវាងកងកម្លាំងថៃ និងប្រជាពលរដ្ឋកម្ពុជា ដើម្បីថែរក្សាស្ថិរភាពបច្ចុប្បន្ន ការពារកុំឱ្យមានការដាក់របាំងបន្លាលួសបន្ថែម និងជៀសវាងសកម្មភាពណាមួយដែលអាចពង្រីកវិសាលភាពនៃជម្លោះ។ ថ្នាក់ដឹកនាំទាំងពីរ ក៏បានផ្ដោតការសន្ទនាអំពីសារៈសំខាន់នៃការរង់ចាំដំណោះស្រាយ ពីកិច្ចប្រជុំរបស់គណៈកម្មការព្រំដែនរួម (JBC) ដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខ តាមការព្រមព្រៀងគ្នារវាងភាគីទាំងពីរ នៅក្នុងកិច្ចប្រជុំពិសេសនៃគណៈកម្មាធិការព្រំដែនទូទៅ (GBC) នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០២៥ កន្លងមក។

**II. សម្ដេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត៖ ជំហរកម្ពុជាក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយភាគីថៃ -- ដោយសន្តិវិធី ដោយផ្អែកលើកិច្ចព្រមព្រៀងទ្វេភាគី អនុសញ្ញា សន្ធិសញ្ញាដែលមានស្រាប់ និងច្បាប់អន្តរជាតិ៖**

ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** បានអនុញ្ញាតឱ្យ ឯកឧត្តម **អូលីវៀរ រីឆាត** (Olivier Richard) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ។

ពាក់ព័ន្ធទៅនឹងស្ថានភាពនៃបញ្ហាព្រំដែនរវាងកម្ពុជា និងថៃ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានឆ្លៀតឱកាសថ្លែងអំណរគុណដល់ប្រធានាធិបតីបារាំង ឯកឧត្តម Emmanuel Macron ដែលបានគាំទ្រដល់បទឈប់បាញ់កន្លងមក។ **សម្តេចធិបតី** ក៏បានជម្រាបជូនឯកឧត្តម ឯកអគ្គរដ្ឋទូតអំពីបច្ចុប្បន្នភាពស្តីពីការវិវត្តនៃស្ថានភាពព្រំដែនកម្ពុជា-ថៃ ដោយគូសបញ្ជាក់អំពីគោលជំហររបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយភាគីថៃ ដោយសន្តិវិធី ដោយផ្អែកលើកិច្ចព្រមព្រៀងទ្វេភាគី អនុសញ្ញា សន្ធិសញ្ញា ដែលមានស្រាប់ និងច្បាប់អន្តរជាតិ។

## III. ករណីឧបទ្ទវហេតុនៅភូមិព្រៃចាន់ ឃុំអូបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ៖

**១-សេចក្តីថ្លែងការណ៍ថ្កោលទោស របស់ក្រសួងមហាផ្ទៃ** នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥– ដោយបានគូសបញ្ជាក់នូវចំណុចសំខាន់ៗមួយចំនួន រួមមាន៖

- "ទង្វើរបស់ថៃ ក៏ជាគំរូអាក្រក់ ដែលមនុស្សជាតិលើពិភពលោកស្អប់ខ្ពើម ហើយបាននិងកំពុងព្យាយាមលុបបំបាត់ ដើម្បីរក្សាគុណតម្លៃនៃបុព្វហេតុរួមរបស់មនុស្សជាតិ គឺការរស់នៅជាមួយគ្នាប្រកបដោយភាពចុះសម្រុង ដោះស្រាយបញ្ហាដោយសន្តិវិធី និងឈរលើយន្តការច្បាប់អន្តរជាតិ។"
- សកម្មភាពរបស់នគរបាល និងកងកម្លាំងចម្រុះថៃគឺជា "ការរំលោភលើសិទ្ធិជាមូលដ្ឋានរបស់មនុស្សជាតិ ជាអាទិ៍ សិទ្ធិលំនៅឋាន សិទ្ធិរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងសិទ្ធិកម្មសិទ្ធិ ដូចមានចែងក្នុងធម្មនុញ្ញអាស៊ាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ធម្មនុញ្ញអង្គការសហប្រជាជាតិ និងលិខិតតុបករណ៍អន្តរជាតិផ្សេងទៀត។"
- សេចក្តីថ្លែងការណ៍ក៏បានគូសរំលេចថា "***មិនត្រូវអនុវត្តច្បាប់អាជ្ញាសឹកថៃ លើដីកម្ពុជាឡើយ***។" ព្រមទាំង "ទទូចឱ្យភាគីថៃ មានសេចក្តីថ្លៃថ្នូរឡើងវិញ ដោយងាកមកគោរពបទឈប់បាញ់ ចូលរួម ពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី និងចូលរួមដោះស្រាយបញ្ហាជាមួយកម្ពុជាប្រកបដោយសន្តិវិធី ស្មោះត្រង់ ឈរលើច្បាប់ និងយន្តការអន្តរជាតិ។"

**២-សេចក្តីថ្លែងការណ៍របស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា–**

- នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានចេញសេចក្តីថ្លែងការណ៍សម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះសុខសុវត្ថិភាពរបស់ប្រជាជនស្លូតត្រង់ក្នុងភូមិព្រៃចាន់ ឃុំអូបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលអាជ្ញាធរថៃបានប្រើអំពើហិង្សាធ្វើឱ្យប្រជាជនស្លូតត្រង់ និងព្រះសង្ឃរងរបួសធ្ងន់ និងស្រាល ចំនួន **២៩អង្គ/នាក់** កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៥ ក្នុងពេលដែលពលរដ្ឋកម្ពុជាកំពុងធ្វើការទាមទារដោយសន្តិវិធីឱ្យមានការគោរពសិទ្ធិរស់រានមានជីវិតលើទឹកដីកំណើតរបស់ខ្លួន។

- ខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះក៏បានថ្កោលទោសដាច់អហង្ការចំពោះសកម្មភាពរបស់កងកម្លាំងរបស់ថៃ ដែលរំលោភយ៉ាងធ្ងន់ធ្ងរលើបទឈប់បាញ់កម្ពុជា-ថៃ ដែលបានធ្វើឡើងកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ នៅប្រទេសម៉ាឡេស៊ី និងការឯកភាពគ្នាក្នុងកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (GBC) និងគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ (RBC) នាពេលកន្លងមក ហើយបានគូសរំលេចថា "***ទង្វើទាំងនេះប៉ះពាល់យ៉ាង ធ្ងន់ធ្ងរដល់ជំនឿទុកចិត្តនយោបាយ និងការខិតខំប្រឹងប្រែងនានាដើម្បីស្តារឡើងវិញនូវសុខសន្តិភាព និងប្រក្រតីភាពនៃទំនាក់ទំនងកម្ពុជា-ថៃ។***"

IV. គិតត្រឹមថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥ ជា**ថ្ងៃទី៥២** ហើយ ដែលវីរកងទ័ពកម្ពុជា ចំនួន **១៨រូប** ត្រូវបានចាប់ឃុំខ្លួនដោយយោធាថៃ ក្រោយបទឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ កម្ពុជាអំពាវនាវឱ្យភាគីថៃ ដោះលែងកងទ័ពកម្ពុជាទាំង ១៨រូប ប្រកបដោយសុខសុវត្ថិភាព ស្របតាមច្បាប់មនុស្សធម៌អន្តរជាតិ។

## Updates on the situation of the Cambodia-Thailand border
## 18-19 September 2025

I. **Samdech Thipadei HUN Manet, Prime Minister of Cambodia urged H.E. Anwar Ibrahim, Prime Minister of Malaysia, the current Chair of ASEAN to intervene promptly to de-escalate the tension between the Thai armed forces –**

On September 18, 2025, **Samdech Thipadei HUN Manet Prime Minister of Cambodia**, had a productive phone discussion with **H.E. Anwar Ibrahim**, Prime Minister of Malaysia and the current ASEAN Chairman—Both leaders discussed the concerning developments of violent incidents committed by Thai armed forces and Thai police over Cambodian civilians in Prey Chan village, O' Bei Choan commune, O' Chrov district, Banteay Meanchey province, which resulting in multiple injuries.

With the ongoing escalation of tensions, **Samdech Thipadei** urged **H.E. Anwar** to intervene promptly to de-escalate the tension between the Thai armed forces and Cambodian civilians, so as to maintain the current stability, prevent further Installation of barbed wire, and avoid any action that could widen the scope of the conflict, emphasized the importance of awaiting a resolution from the upcoming meeting of the Joint Boundary Commission ( JBC ) in accordance with the agreement reached by both parties during the special General Border Committee ( GBC ) meeting held on September 10, 2025.

II. **Samdech Thipadei HUN Manet: Cambodia's position in resolving the border issue with the Thai side peacefully, based on the existing bilateral agreements, conventions, treaties, and in accordance with international law:**

On 19 September 2025, Samdech Thipadei Hun Manet, Prime Minister of the Kingdom of Cambodia, received a courtesy call from His Excellency Olivier Richard, Ambassador Extraordinary and Plenipotentiary of the French Republic to the Kingdom of Cambodia.

During the meeting, the two sides discussed a wide range of matters of mutual interest, including the Cambodia–Thailand border issue. Samdech Thipadei Prime Minister took the opportunity to express his appreciation to President Emmanuel Macron for his support of the ceasefire. He also briefed the French Ambassador on the recent developments regarding the Cambodia–Thailand border situation, and reaffirmed Cambodia's steadfast position to resolve the issue peacefully, on the basis of existing bilateral agreements, conventions, and treaties, and in full conformity with international law.

III. **On the violent incident committed by Thai armed forces and Thai police at Prey Chan village, O Bei Choan commune, O Chrov district, Banteay Meanchey province:**

**1- Statement of Condemnation by the Ministry of Interior,** on September 18, 2025 — emphasized the following key points:

- "Thailand's actions represent a negative example that the international community has long condemned and continues to strive to eliminate, in order to uphold the shared values of humanity—living together in harmony, resolving disputes peacefully, and abiding by international law."
- The actions undertaken by the Thai armed forces "infringe upon fundamental human rights, including the right to housing, the right to live in dignity, and property rights, as recognized in the ASEAN Charter, the Universal Declaration of Human Rights, the United Nations Charter, and other international legal instruments."
- The statement highlighted that "*Thai martial law shall not be enforced on Cambodian soil,*" and further called on the Thai side to act with responsibility and restraint, respect the ceasefire, strengthen the implementation of bilateral agreements, and resolve issues with Cambodia in a peaceful, sincere manner, fully adhering to international law and procedures.

2- Statement of the National Assembly of the Kingdom of Cambodia—

On September 19, 2025, the National Assembly issued a statement expressing its deep concern for the safety and well-being of innocent people in Prey Chan village, O' Bei Choan commune, O' Chrov district, Banteay Meanchey province, where Thai authorities resorted to violence, causing serious and minor injuries to 29 innocent people and Buddhist monks on September 17, 2025, while Cambodian citizens were peacefully demanding respect for their right to life in their homeland.

The statement strongly condemned the actions undertaken by the Thai armed forces, which constitute a grave violation of the Ceasefire reached by both parties on July 28, 2025, in Malaysia, as well as the agreements adopted in the GBC and the RBC meetings. It also emphasized that "***Thailand's actions seriously undermine political trust and efforts to restore peace and normality in Cambodia-Thai relations***".

IV. As of September 19, 2025, it has been **52** days since **18** Cambodian soldiers were captured under captivity of the Thai military. Cambodia urgently calls on the Thai side to release them as soon as possible, in accordance with international humanitarian law.